ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ០៧៤/២៣ អអរ**

## សេចក្ដីប្រកាសព័ត៌មាន

## លទ្ធផលនៃសន្និសីទសារព័ត៌មានស្ដីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តប៉ៃលិន"

នាព្រឹកថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តប៉ៃលិន»** ដែលមានវាគ្មិនចូលរួមគឺៈ

- **លោកជំទាវ បាន ស្រីមុំ អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តប៉ៃលិន**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យ ដែលរដ្ឋបាលខេត្តប៉ៃលិន ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយឋាមពលរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

### I. ស្ថានភាពទូទៅ

ខេត្តប៉ៃលិន មានផ្ទៃដីសរុប ១.១៩៤,៦១ គីឡូម៉ែត្រក្រឡា បែកចេញជាក្រុង១ ស្រុក១ ឃុំ-សង្កាត់៨ និងមានភូមិចំនួន៩៧ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ៧៨.៩៧៥នាក់ ស្មើនឹង ១៨.៥៨២ គ្រួសារ។ ទំហំសេដ្ឋកិច្ចខេត្តសរុបចំនួន ១២០លានដុល្លារ ស្មើនឹង ០,៤៣% នៃសេដ្ឋកិច្ចជាតិ ដោយក្នុងឆ្នាំ២០២២ ចំណូលជាមធ្យមរបស់ប្រជាពលរដ្ឋម្នាក់ចំនួន ១.៤៦៧,៨ដុល្លាអាមេរិក មានការកើនឡើងចំនួន៤២០ដុល្លាអាមេរិក ស្មើនឹង ២៨,៦៨% បើធៀបនឹងឆ្នាំ២០១៧ មានត្រឹម ១.០៤៧,៧ ដុល្លាអាមេរិកប៉ុណ្ណោះ។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយជីវភាពរបស់ប្រជាពលរដ្ឋ អំឡុងពេលសង្គមជាតិប្រឈមនឹងវិបត្តិផ្សេងៗ ជាក់ស្តែង បានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ សរុប ៥.៧៨៥នាក់ ចំណាយថវិកា ២២.៩០៦.១៤៩.០០០រៀល, គ្រួសារក្រីក្រអំឡុងពេលបិទខ្ទប់ចំនួន ៣៤គ្រួសារ ចំណាយថវិកា ១០.០៣៩.៩០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួន ១.៩៨៨នាក់ ចំណាយថវិកា ៩២៤.៦៣០.០០០រៀល និងឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យសរុប ២.៣៧១គ្រួសារ អស់ថវិកា ៣៦៧.១៧៤.៣០០រៀល។
- **វិស័យកសិកម្ម៖** រដ្ឋបាលខេត្ត បានខិតខំជម្រុញនូវយន្តការអភិវឌ្ឍផ្នែកវិស័យកសិកម្ម ដូចជាការអប់រំ បណ្តុះបណ្តាលបច្ចេកទេសក្នុងការប្រើប្រាស់ជី ការប្រើប្រាស់ ថ្នាំកសិកម្ម ជម្រុញនូវការប្រើប្រាស់ពូជប្រកបដោយគុណភាពដល់ប្រជាកសិករ ការធ្វើពិពិធកម្មរូបនីយកម្ម ការចិញ្ចឹមសត្វ និងការគាំទ្រសហគមន៍កសិកម្ម ក្នុងគោលដៅបង្កើនទិន្នផល ធានាបាននូវសន្តិសុខស្បៀង បង្កើនប្រាក់ចំណូល និងលើកកម្ពស់សេដ្ឋកិច្ចគ្រួសារកាត់បន្ថយភាពក្រីក្រ។ ជាក់ស្តែង ទូទាំងខេត្ត ផ្ទៃដីដាំដុះដំណាំស្រូវមានចំនួន ៨.៩៣០ ហិកតា ទទួលបានទិន្នផលសរុប ចំនួន ១២៤.៣៦៨ តោន ដំណាំសាកវប្បកម្មចំនួន ១២.២៩៧ ហិកតា ទិន្នផល ៥៩៤.៣៧៦ តោន និងដំណាំឧស្សាហកម្មចំនួន ៥១.៧៥៩ ហិកតា ទទួលបានទិន្នផល ៤.០៤១.៨៤៥ តោន។ ជាមួយគ្នានេះ រដ្ឋបាលខេត្តក៏បានយកចិត្តទុកដាក់ក្នុងការកសាងនូវប្រព័ន្ធធារាសាស្ត្រ ក្នុងន័យទ្រទ្រង់នូវការផ្គត់ផ្គង់ទឹកទូទាំងខេត្ត ទ្រទ្រង់ដល់វិស័យកសិកម្ម ទប់ស្កាត់ ហានិភ័យដែលបណ្តាលមកពីគ្រោះធម្មជាតិ ទឹកជំនន់ គ្រោះរាំងស្ងួត តាមរយៈការបន្តជីកប្រឡាយ និងបន្តសាងសង់សំណង់ធារាសាស្ត្រគ្រប់ប្រភេទបន្ថែមទៀត ស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ។
- **វិស័យទេសចរណ៍៖** ជាភូមិសាស្ត្រសម្បូរដោយធនធានធម្មជាតិ ដែលជាសក្តានុពលដល់វិស័យទេសចរណ៍ ដោយខេត្តប៉ៃលិន ទទួលបានភ្ញៀវទេសចរមកទស្សនាសរុបចំនួន ៩៧០.៥៤៩នាក់ ក្នុងនោះមាន ភ្ញៀវទេសចរជាតិចំនួន ៩៦៣.៤២៤ នាក់ និងភ្ញៀវទេសចរអន្តរជាតិចំនួន ៧.១២៥នាក់ បើប្រៀបធៀបនឹង៥ឆ្នាំមុន មានការកើនឡើងគួរឱ្យកត់សម្គាល់។
- **ការផ្តល់សេវាសាធារណៈ៖** រដ្ឋបាលខេត្ត បានជំរុញ លើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមរយៈយន្តការច្រកចេញ-ចូលតែមួយថ្នាក់ខេត្ត ក្រុង ស្រុក ព្រមទាំងបានពង្រីកដល់មូលដ្ឋានឃុំ-សង្កាត់ ដោយស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល កាត់បន្ថយការិយាធិបតេយ្យ អំពើពុករលួយ មានគណនេយ្យភាព តម្លាភាព បង្កិតសេវាកាន់តែជិត

ប្រជាពលរដ្ឋ ចំណាយថវិកាតិច និងបង្កើនប្រាក់ចំណូលចូលថវិកាជាតិ។ បច្ចុប្បន្ន យន្តការនេះ បានផ្តល់សេវាលើវិស័យ ចំនួន១៥ ស្មើនឹង ៣៣.៧៩៩សេវា។

- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត៖** រដ្ឋបាលខេត្ត បានខិតខំជំរុញការអភិវឌ្ឍទៅលើការងារហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ផ្លូវថ្នល់ ការសាងសង់បណ្តាញផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ការថែរក្សាអនាម័យ សោភណភាពបរិស្ថានជាដើម ក្នុងន័យបម្រើផលប្រយោជន៍ផ្ទាល់របស់ប្រជាពលរដ្ឋមូលដ្ឋាន។ ដោយបច្ចុប្បន្ននេះ ទូទាំងខេត្តប៉ៃលិនទាំងមូល ប្រែក្លាយពីកន្លែងអត់ផ្លូវ ធ្វើឱ្យមានផ្លូវ និងបានគ្របដណ្តប់ដោយផ្លូវកៅស៊ូ និងបេតុងប្រមាណ ៩០% ព្រមទាំងសម្រេចបាននូវការអនុវត្តគម្រោង ODF បាន៧៥% ជាមួយគ្នានេះ រដ្ឋបាលខេត្តបានប្តេជ្ញាសម្រេចឱ្យបាននូវការប្រកាសទទួលស្គាល់ខេត្តប៉ៃលិន ជាផ្លូវការថាជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) និងការកែប្រែពីផ្លូវដី ផ្លូវក្រាលគ្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងទាំងអស់ ក្នុងពេលឆាប់ៗខាងមុខនេះ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្តប៉ៃលិន បន្តលើកកម្ពស់ការរក្សាសន្តិសុខនយោបាយ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំផែនការ និងជម្រុញល្បឿន ក្នុងការអភិវឌ្ឍខេត្ត ឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ទាំងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកបរិស្ថាន និងផ្នែកសាធារណការ ជាពិសេសការផ្តល់សេវាសាធារណៈ ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែប្រសើរឡើង ក្នុងនោះរដ្ឋបាលខេត្តបានខិតខំស្រាវជ្រាវ ស្វែងរកផលិតផលដែលជាសក្តានុពលរបស់ខេត្ត ដើម្បីជម្រុញនូវចលនា **"ភូមិ១ ផលិតផល១"** សំដៅបង្កើតការងារនៅមូលដ្ឋានផ្ទាល់ កាត់បន្ថយការធ្វើចំណាកស្រុក អភិវឌ្ឍន៍នូវចំណេះដឹង និងបច្ចេកទេសដល់ប្រជាពលរដ្ឋ លើកស្ទួយផលិតផលខ្មែរ ទាំងបរិមាណ និងគុណភាពឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុងស្រុក និងសម្រាប់នាំចេញទៅក្រៅប្រទេស ព្រមទាំងអាចទាក់ទាញវិនិយោគិនក៏ដូចជាភ្ញៀវទេសចរឱ្យមកកំសាន្តនៅក្នុងខេត្តបន្ថែមទៀត។ ជាមួយគ្នានេះ បន្តពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព" ឱ្យកាន់តែល្អប្រសើរ ដើម្បីភាពសុខដុមរមនារបស់ប្រជាពលរដ្ឋ៕

ថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣